**CAMBREW LTD**

Part of the Carlsberg Group













# ខេមប្រ៊ូវ ក្នុងដំណើរឆ្ពោះទៅកាន់ «គ្មានការពិសាគ្រឿងស្រវឹង ដោយគ្មានទំនួលខុសត្រូវ»










ខេមប្រ៊ូវ បានសហការជាមួយដៃគូពាក់ព័ន្ធនៅថ្នាក់ជាតិ និងរដ្ឋបាលរាជធានីភ្នំពេញ បើកយុទ្ធនាផ្សព្វផ្សាយអំពីការពិសាគ្រឿងស្រវឹងដោយការទទួលខុសត្រូវ។

យុទ្ធនាការក្រោមសារ «ពិសាគ្រឿងស្រវឹង សូមកុំបើកបរ»នេះមានគោលបំណងលើក កម្ពស់ការយល់ដឹងជាសាធារណៈ និងអប់រំអ្នកប្រើប្រាស់អំពីការទទួលទានគ្រឿងស្រវឹង ដោយការទទួលខុសត្រូវ។

អគ្គនាយកដ្ឋានការពារអ្នកប្រើប្រាស់ កិច្ចការប្រកួតប្រជែង និងបង្ក្រាបការក្លែងបន្លំ (ក.ប.ប.) ក្រសួងអប់រំ យុវជន និងកីឡា និងរដ្ឋបាលរាជធានីភ្នំពេញ ដែលបានចូលរួមគាំទ្រយុទ្ធនាការនេះយ៉ាងពេញទំហឹង ក៏ចង់ឃើញការផ្លាស់ប្តូរឥរិយាបថជាវិជ្ជមានរបស់អ្នកប្រើប្រាស់ ដោយចាប់ផ្តើមពិសាគ្រឿងស្រវឹងហើយ មិនត្រូវបើកបរ។














យុទ្ធនាការនេះ បានប្រព្រឹត្តទៅក្រោមអធិបតីភាពរបស់ ឯកឧត្តម ផាន អូន ប្រតិភូរាជ រដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋាន ក.ប.ប.  ឯកឧត្តម សោម រតនា អនុរដ្ឋលេខាធិការ ក្រសួងអប់រំ យុវជន និងកីឡា ឯកឧត្តម នួន ផារ័ត្ន អភិបាលរងនៃគណៈអភិបាលរាជធានីភ្នំពេញ និងលោក Vladimir Vava អគ្គនាយកគ្រប់គ្រងក្រុមហ៊ុន ខេមប្រ៊ូវ។

ពិធីនេះមានអ្នកចូលរួមជាង១០០នាក់ មកពីវិស័យផ្សេងៗ រួមមានទាំងវិស័យសាធារណៈ ឯកជន សមាគមពាណិជ្ជកម្ម អង្គការក្រៅរដ្ឋាភិបាល ក្រុមហ៊ុនផលិតស្រាបៀរ ក្រុមហ៊ុនដឹកជញ្ជូន និងយុវជន ក៏ដូចជាអ្នកបើកបររ៉ឺម៉កកង់បីជាដើម។

ព្រឹត្តិការណ៍នេះ មិនត្រឹមតែជាថ្ងៃសក្ខីភាពនៃការចាប់ផ្តើមយុទ្ធនាការប៉ុណ្ណោះទេ តែក៏ដើម្បី បន្ទរផ្សព្វផ្សាយឲ្យកាន់តែទូលំទូលាយអំពី «ការពិសាគ្រឿងស្រវឹងដោយទំនួលខុសត្រូវ» និងប្រកាសស្វែងរកដៃគូបន្ថែម ដើម្បីចូលរួមក្នុងដំណើរនេះជាមួយ ខេមប្រ៊ូវ ព្រោះថាយើង ម្នាក់ៗ សុទ្ធតែជាអ្នកដឹកនាំដ៏សំខាន់ ដើម្បីបង្កើតការផ្លាស់ប្តូរជាវិជ្ជមានឲ្យសង្គមរបស់យើង កាន់តែប្រសើរ។








វីដេអូ និងសារអប់រំ អំពីការទទួលទានគ្រឿងស្រវឹងដោយទទួលខុសត្រូវ បានកំពុងបង្ហោះ ផ្សព្វផ្សាយជាបន្តបន្ទាប់នៅលើប្រព័ន្ធបណ្តាញសង្គមរបស់ ខេមប្រ៊ូវ ក៏ដូចជាចែករំលែក នៅលើទំព័រដៃគូផ្សព្វផ្សាយ និងសារព័ត៌មានផ្សេងៗទៀតផងដែរ។

«គ្មានការពិសាគ្រឿងស្រវឹងដោយគ្មានការទទួលខុសត្រូវ» ត្រូវបានដាក់បញ្ចូលទៅក្នុង យុទ្ធសាស្រ្តអាជីវកម្ម ដែលមានទាំងគោលដៅ និងផែនការសកម្មភាពជាក់លាក់ និងជា ផ្នែកមួយនៃគោលបំណងនិរន្តរភាពរបស់ក្រុមហ៊ុន គឺ«អភិវឌ្ឍឲ្យកាន់តែប្រសើរទាំងថ្ងៃនេះ ៥ថ្ងៃស្អែក»។ យើងមានសុទិដ្ឋិនិយមថា ក្រោមកិច្ចសហការ ការជួយជ្រោមជ្រែង និងការខិតខំប្រឹងប្រែងរបស់រដ្ឋាភិបាល អតិថិជន អ្នកប្រើប្រាស់ និងការចូលរួមពីដៃគូពាក់ព័ន្ធ នានានៃឧស្សាហកម្មគ្រឿងស្រវឹង គឺជាគន្លឹះដ៏សំខាន់ ដែលនឹងផ្លាស់ប្តូរឥរិយាបថរបស់អ្នក ប្រើប្រាស់ប្រកបដោយភាពវិជ្ជមាន។

# ខេមប្រ៊ូវ រួមចំណែកក្នុងសកម្មភាព ថែរក្សាបរិស្ថាន និងបណ្ដុះវប្បធម៌ ចែករំលែក




យើងមានក្ដីសោមនស្សរីករាយ ដែលបានក្លាយជាចំណែកមួយក្នុងសកម្មភាពការពារបរិស្ថាន និងជំរុញការអប់រំដល់កុមារ តាមរយៈការគាំទ្រកម្មវិធី «ដាំកូនឈើ នឹងកៀរគរ ធនធានដើម្បីកុមារក្រៅសាលារៀន» ដែលរៀបចំឡើងដោយអង្គការយុវតារា កាលពីចុងខែឧសភា ឆ្នាំ២០២៣។

ព្រឹត្តិការណ៍នេះ រៀបចំឡើងក្រោមប្រធានបទ «ជំរំយុវជនដើម្បីការអប់រំ និងការទទួលខុសត្រូវចំពោះបរិស្ថាន» នៅសាលាបឋមសិក្សាសង្គម ស្រុកសំបូរ ខេត្តក្រចេះ រួមជាមួយ សកម្មភាពជាច្រើន រួមមាន ការសម្អាតបរិស្ថានក្នុងសហគមន៍ ការដាំដើមឈើ ការគូរគំនូរនៅតាមអគារសិក្សា ព្រមទាំងចែកសម្ភារៈសិក្សាជូនដល់សិស្សានុសិស្ស ប្រមាណ២០០នាក់។

ស្របតាមចក្ខុវិស័យ អភិវឌ្ឍឲ្យកាន់តែប្រសើរទាំងថ្ងៃនេះ ៥ថ្ងៃស្អែក ខេមប្រ៊ូវ បាន និងកំពុងដឹកនាំអាជីវកម្មដែលមានទំនួលខុសត្រូវខ្ពស់ និងយកចិត្តទុកដាក់លើ បរិស្ថាន ការអប់រំសុខុមាលភាព ពិពិធភាព សមធម៌ ៥បរិយាបន្ននៅកន្លែងការងារ និងក្នុងសង្គម ក៏ដូចជាចូលរួមចំណែកជួយសហគមន៍ឲ្យកាន់តែប្រសើរ។

ក្នុងនាមជាក្រុមហ៊ុន ដែលមានប្រតិបត្តិការលើរោងចក្រស្រាបៀរដំបូងគេបំផុតនៅកម្ពុជា យើងជឿជាក់ថា សកម្មភាពសង្គមដែលយើងបាននិងកំពុងចូលរួម នឹងធ្វើឱ្យ ខេមប្រ៊ូវ នៅតែបន្តនាំមុខគេមួយក្នុងកិច្ចការងារសង្គម និងភាពជាគំរូក្នុងការបណ្ដុះវប្បធម៌ និងស្មារតីជួយគ្នាទៅវិញទៅមក។

# ខេមប្រ៊ូវ រួមចំណែកអភិវឌ្ឍ ធនធានមនុស្ស ដើម្បីសង្គមកាន់តែប្រសើរ







ស្របតាមគោលដៅចីរភាព «ការអភិវឌ្ឍឲ្យកាន់តែប្រសើរទាំងថ្ងៃនេះ និងថ្ងៃស្អែក» យើងមានកិត្តិយស ដែលបានចូលរួមគាំទ្រដល់ក្រសួងបរិស្ថាន ក្នុងការរៀបចំ «វេទិកាជើងឯកយុវជនជជែកពិភាក្សាអំពីបរិស្ថាន ឆ្នាំ២០២៣»។

វេទិកានេះរៀបចំឡើង ក្នុងគោលបំណងជំរុញចលនាយុវជនស្រឡាញ់បរិស្ថាន បង្កើនការសិក្សាស្រាវជ្រាវ ជជែកពិភាក្សាស៊ីជម្រៅអំពីបរិស្ថាន ព្រមទាំងចែករំលែកចំណេះដឹង ពាក់ព័ន្ធនឹងបរិស្ថានទៅកាន់សាធារណជន ដែលសកម្មភាពនេះ ស្របនឹងទស្សនវិស័យ របស់ ខេមប្រ៊ូវ ក្នុងការចូលរួមចំណែកអភិវឌ្ឍធនធានមនុស្ស បរិស្ថាន និងសង្គម។

យើងរួមគ្នា ដើម្បីនិរន្តរភាពបរិស្ថាន និងការរស់នៅប្រកបដោយចីរភាព។ ជាមួយនឹងគោលដៅចីរភាពថ្មីស្តីពីបរិស្ថាន សង្គម និងអភិបាលកិច្ច «រួមគ្នាឆ្ពោះទៅកាន់ហ្សេរ៉ូ និងលើសពីនេះ (TTZAB)» ប្រកបដោយមហិច្ឆតារបស់យើង នឹងនាំយើង ឆ្ពោះទៅសម្រេចបាននូវចក្ខុវិស័យដែលជាអនាគតដ៏ប្រសើរសម្រាប់យើងទាំងអស់គ្នា។

CAMBREW LTD
Part of the Carlsberg Group



# យើងចែករំលែកក្តីស្រឡាញ់ជាមួយកុមារ និងកសាងអនាគតដ៏ប្រសើររួមគ្នា











កុមារ គឺកម្លាំងចលករដ៏សំខាន់ និងជាធនធានដ៏មានតម្លៃបំផុតរបស់សហគមន៍ ដែលនឹងចូលរួមអភិវឌ្ឍសហគមន៍របស់ពួកគេ ឲ្យកាន់តែប្រសើរនាពេលអនាគត។ យើង ចង់ឃើញកុមារគ្រប់រូបទទួលបានការអប់រំប្រកបដោយបរិយាបន្ន និងធំធាត់ឡើងជាមួយនឹងក្តីស្រឡាញ់ ការយកចិត្តទុកដាក់ពីសង្គម និងវប្បធម៌នៃការចែករំលែក។

ហេតុដូច្នេះហើយបានជា ខេមប្រ៊ូវ មិនស្ទាក់ស្ទើរក្នុងការចូលរួមប្រារព្ធទិវាកុមារអន្តរជាតិ «បេះដូងលោតក្នុងចង្វាក់តែមួយ ចែករំលែកក្តីស្រឡាញ់» ជាមួយដៃគូ និងយុវជន នៅសាលាបឋមសិក្សាចំនួនពីរ គឺសាលាបឋមសិក្សា គីរីអណ្តែត និងសាលាបឋមសិក្សា ព្រៃវែង ស្ថិតក្នុងស្រុកតាំងគោក ខេត្តកំពង់ធំ។

ការចូលរួមចំណែករបស់យើង គឺជាសក្ខីភាពបញ្ជាក់ពីការប្តេជ្ញាចិត្តរបស់ ខេមប្រ៊ូវ ក្នុងការលើកស្ទួយសិទ្ធិ សេរីភាព និងលើកកម្ពស់សុខុមាលភាពរបស់កុមារនៅក្នុងសហគមន៍ដែលយើងមានប្រតិបត្តិការអាជីវកម្ម។ ខេមប្រ៊ូវ ប្តេជ្ញាចិត្តចូលរួមកសាងធនធានមនុស្សដែលពោរពេញដោយគុណភាព ស្នាមញញឹម ក្តីស្រឡាញ់ ចេះចែករំលែក ដើម្បីអនាគតដ៏ប្រសើររួមគ្នា។

# ខេមប្រ៊ូវ បន្តឆន្ទៈគាំទ្រ និងអភិវឌ្ឍធនធានមនុស្ស









ខេមប្រ៊ូវ មានក្តីសោមនស្សរីករាយ ដោយបានចូលរួមឧបត្ថម្ភទឹកបរិសុទ្ធចំនួន ១៥០កេស ដល់អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ សម្រាប់ទ្រទ្រង់ដល់ការរៀបចំមិទ្ទិញអបអរសាទរខួបលើកទី៧៤ ទិវាកុមារអន្តរជាតិ ១មិថុនា និងខួបលើកទី២២ ទិវាពិភពលោកប្រឆាំងពលកម្មកុមារ ១២មិថុនា ដែលទើបប្រារព្ធ នាថ្ងៃទី១ មិថុនា កន្លងទៅ។

ខេមប្រ៊ូវ នៅតែចូលរួមក្នុងសកម្មភាពដែលពាក់ព័ន្ធនឹងការគាំទ្រ និងអភិវឌ្ឍធនធានមនុស្ស ដើម្បីស្អាមញញឹមរបស់កម្ពុជា។ យើងក៏ប្តេជ្ញាយ៉ាងមុតមាំ នៅក្នុងការធ្វើប្រតិបត្តិអាជីវកម្មប្រកបដោយការទទួលខុសត្រូវទាំងសង្គម បរិស្ថាន និងអភិបាលកិច្ច ជាមួយនឹងឆន្ទៈចូលរួមអភិវឌ្ឍសង្គមឱ្យកាន់តែប្រសើរ ទាំងថ្ងៃនេះ និងថ្ងៃស្អែក។

# អបអរទិវាបុណ្យឯករាជ្យអាមេរិកលើកទី២៤៧ និងបង្កើតអនុស្សាវរីយ៍ដ៏រីករាយជាមួយ ប៉ិបស៊ី













ក្រុមហ៊ុន ខេមប្រ៊ូវ មានកិត្តិយសដែលបានចូលរួមក្នុងកម្មវិធីអបអរទិវាឯករាជ្យអាមេរិកលើកទី២៤៧ ដែលរៀបចំជារៀងរាល់ឆ្នាំ ហើយឆ្នាំនេះ គឺនៅថ្ងៃទី០៤ កក្កដា។

ប៉ិបស៊ី ក៏បានចូលរួមអបអរជ័យជម្នះ និងបានធ្វើឱ្យពិធីនេះ កាន់តែមានបរិយាកាសសប្បាយរីករាយកាន់តែឱឡារិក និងជាទិដ្ឋភាពដ៏គួរឲ្យចង់ចាំ ក៏ដូចជា បង្កើតអនុស្សាវរីយ៍ដ៏រីករាយជាមួយគ្នា។ យើងក៏ទទួលបានបានការថ្លែងអំណរគុណដោយផ្ទាល់មាត់ និងជាសារលិខិត ពីឯកអគ្គរដ្ឋទូតអាមេរិកប្រចាំនៅកម្ពុជា W. Patrick Murphy។

ក្នុងនាមជាក្រុមហ៊ុនដែលមានទំនួលខុសត្រូវសង្គមលេចធ្លោមួយនៅកម្ពុជា ខេមប្រ៊ូវ ប្តេជ្ញាផ្តល់នូវភាពរីករាយ បង្កើនភាពស្និទ្ធស្នាល និងចូលរួមអបអរជ័យជម្នះជាមួយគ្នា តាមរយៈការផ្តល់នូវជម្រើសភេសជ្ជៈជាច្រើនប្រភេទ ដែលស័ក្តិសមគ្រប់ពេលវេលាជូនអតិថិជន។

# នៅកាសស្បែរ យើង «ស្វាគមន៍អ្នក» ទាំងអស់គ្នា ដោយពិពិធភាព សមធម៌ និងបរិយាបន្ន




ភាពខុសប្លែកពីគេរបស់យើង ជាអ្វីដែលធ្វើឱ្យយើងរួបរួមគ្នា។ ក្នុងនាមជាក្រុមហ៊ុនដែល មានកេរ្តិ៍ឈ្មោះល្បីល្បាញនៅទូទាំងពិភពលោក កាសស្បែរ ពឹងផ្អែកលើការរួបរួមកម្លាំងគ្នា របស់សហសេវិកទាំងអស់ ដើម្បីជំរុញឱ្យយើងឈានទៅកាន់ចំណុចដែលលេចធ្លោក្នុងឧស្សាហកម្មនេះ។ នេះគឺជាមូលហេតុដែលនៅ កាសស្បែរ យើងត្រូវតែធានាថាសហសេវិកគ្រប់រូបត្រូវបានរាប់បញ្ចូល សំឡេងពួកគេត្រូវបានដឹងឮ ហើយលើសពីនេះទៀតនោះ គឺយើងស្វាគមន៍ចំពោះភាពជាខ្លួនគេនៅកន្លែងធ្វើការ។

ស្វាគមន៍អ្នក គឺជាវិធីសាស្រ្តថ្មីមួយទៀត បន្ថែមលើទស្សនវិជ្ជាដែលត្រូវបានបង្កើតឡើងយ៉ាងយកចិត្តទុកដាក់ និងប៉ិនប្រសប់ ក្នុងគោលបំណងនាំយកសក្តានុពលពីពិពិធភាព សមធម៌ និងបរិយាបន្ន (DE&I) ដែលទាំងអស់គ្នា អាចទទួលបានគុណប្រយោជន៍ពីឆន្ទៈនេះ។

ភាពបន់បែននៃពិពិធភាព សមធម៌ និងបរិយាបន្ន អនុញ្ញាតឱ្យសហសេវិករបស់យើងបង្ហាញចេញនូវគុណសម្បត្តិ សមត្ថភាព ទេពកោសល្យ ជំនាញរបស់ពួកគេ ទន្ទឹមនឹងការរក្សាឆន្ទៈក្នុងការរីកចម្រើនទៅមុខ កិច្ចសហប្រតិបត្តិការ ការយោគយល់ និងសមត្ថភាពក្នុងការស្វែងរកនូវភាពខ្វះចន្លោះនានា។




ពិពិធភាព សមធម៌ និងបរិយាបន្ន ជាមួយនឹងកម្មវិធី «ស្វាគមន៍អ្នក» យើងអាចមើលឃើញពីសក្តានុពលរបស់បុគ្គល ក្នុងការមិនប្រកាន់ភេទ អាយុ សាសនា ជាតិសាសន៍ វណ្ណៈ និងពណ៌សម្បុរនោះឡើយ។ ដូច្នេះទើប កាសស្បឺរ បានប្រឹងប្រែងយ៉ាងខ្លាំង ក្នុងការបង្ហាញការយកចិត្តទុកដាក់របស់យើង ដល់អ្នកដែលមានលក្ខណៈសម្បត្តិពេញលេញ ក្នុងការនាំមកនូវការផ្លាស់ប្តូរទៅកាន់សហគមន៍ជុំវិញខ្លួនពួកគេ។

យើងសាទរចំពោះភាពខុសប្លែកពីគេរបស់យើង ហើយយើងបន្តប្តេជ្ញាចិត្តធ្វើការរួមគ្នា ដើម្បីឆ្ពោះទៅរកភាពដ៏ល្អប្រសើរលេចធ្លោជាមួយគ្នា។

# ខេមប្រ៊ូវ ចូលរួមប្រារព្ធបុណ្យ Pride និងបន្តលើកកម្ពស់ពិពិធភាព សមធម៌ &បរិយាបន្ន នៅកន្លែងធ្វើការ







ពិធីបុណ្យ Pride តែងតែប្រារព្ធឡើងរៀងរាល់ខែមិថុនា ដើម្បីអបអរ និងសាទរដល់ការចូលរួមរបស់ LGBTQ+ នៅក្នុងកិច្ចអភិវឌ្ឍនានា។

នៅខេមប្រ៊ូវ យើងបានដាក់បញ្ចូលនូវពិពិធភាព សមធម៌ &បរិយាបន្ន (DE&I) ជាគោលគន្លឹះស្នូលយ៉ាងសំខាន់ចំពោះពួកយើង។ យើងគ្រប់គ្នាមកពីកន្លែង និងមានប្រវត្តិខុសៗគ្នា ហើយពួកយើងមានលក្ខណៈពិសេសផ្សេងៗគ្នា រួមទាំងជំនាញ និងទស្សនៈ។ ភាពចម្រុះនេះហើយ គឺជាអត្តសញ្ញាណរបស់យើង ហើយក៏ជាអ្វីដែលធ្វើឱ្យយើងមានភាពលេចធ្លោ។

ភាពជោគជ័យរបស់យើង គឺពឹងផ្អែកលើ DE&I ដែលជាកម្លាំងដ៏អស្ចារ្យ ហើយនេះជាមូលហេតុដែលខេមប្រ៊ូវ ធានាថាសហសេវិករបស់យើងទាំងអស់ ទទួលស្គាល់ថាពួកគេត្រូវបានរួមបញ្ចូល និងទទួលបានការទទួលស្គាល់យ៉ាងពេញលេញ។ លើសពីនេះទៀត នៅ ខេមប្រ៊ូវ ពួកយើងរីករាយស្វាគមន៍ភាពជាខ្លួនឯងរបស់សហសេវិកគ្រប់រូប។

ខេមប្រ៊ូវ ជឿជាក់ថា ការរួបរួមកម្លាំងគ្នារបស់យើង នឹងជះឥទ្ធិពលជាវិជ្ជមានបន្ថែមទៀតដល់ការលើកកម្ពស់ពិពិធភាព សមធម៌ &បរិយាបន្ននៅកន្លែងធ្វើការ ដើម្បីអភិវឌ្ឍឲ្យកាន់តែប្រសើរទាំងថ្ងៃនេះ និងថ្ងៃស្អែក។

# ខេមប្រ៊ូវ ចូលរួមអបអរទិវាលោកឪពុក ដោយចែករំលែកពាក្យពេចន៍ក្នុងចិត្តកូន ទៅកាន់ លោកឪពុក




ទិវាលោកឪពុក ត្រូវបានប្រារព្ធឡើងដើម្បីរំឭកដល់គុណូបការរបស់លោកឪពុកគ្រប់រូប ដែលបានខិតខំ និងលះបង់ឥតនឿយហត់ ដើម្បីចិញ្ចឹមបីបាច់ និងតម្រង់ផ្លូវកូនៗ ឱ្យក្លាយ ជាធនធានមនុស្សដ៏មានសក្តានុពល ដែលអាចជួយអភិវឌ្ឍសង្គមជាតិកាន់តែប្រសើរ។

ក្រុមហ៊ុន ខេមប្រ៊ូវ សូមកោតសរសើរដល់ទឹកចិត្តដ៏មោះមុត ការលះបង់ និងក្តីស្រលាញ់របស់លោកពុកចំពោះកូន  និងសូមគោរពជូនពរលោកឪពុកគ្រប់រូប មានសុខភាពល្អមាំមួន ជានិច្ច។




យើង ក៏បានផលិតនូវវីដេអូខ្លីមួយ ដែលជាសាច់រឿងពិតរបស់សហសេវិកម្នាក់របស់យើង ចែករំលែកនៅលើប្រព័ន្ធផ្សព្វផ្សាយសង្គមរបស់ខេមប្រ៊ូវ៖ Cambrew Ltd ផងដែរ។ ក្នុងវីដេអូនេះ គាត់បានរៀបរាប់អនុស្សាវរីយ៍ពីអតីតកាលជាមួយលោកពុក និងពាក្យពេចន៍ក្នុងចិត្តដែលគាត់មិនធ្លាប់និយាយទៅកាន់លោកពុក។

# ការចូលរួមរបស់សហសេវិក និងវប្បធម៌ពិពិធភាព សមធម៌ និងបរិយាបន្ន (DE&I) របស់ខេមប្រ៊ូវ ទទួលបានការសាទរយ៉ាងខ្លាំងពីសហសេវិក




សហសេវិករបស់ ខេមប្រ៊ូវ បានបង្ហាញអារម្មណ៍ពេញចិត្តជាខ្លាំង ចំពោះវប្បធម៌លើកកម្ពស់ពិពិធភាព សមធម៌ និងបរិយាបន្ន (DE&I) របស់ក្រុមហ៊ុន។

លទ្ធផលនៃការស្ទង់មតិ My Voice ឆ្នាំ២០២៣ បង្ហាញថា ពិន្ទុសម្រាប់ពិពិធភាព សមធម៌ ៥បរិយាបន្ន មានចំនួន ៧៨% ដែលនេះក៏បញ្ជាក់អំពីការពេញចិត្តរបស់សហសេវិក ចំពោះវប្បធម៌ពិពិធភាព សមធម៌ ៥បរិយាបន្ន ដែលយើងកំពុងតម្រង់ឆ្ពោះទៅ។

លទ្ធផលនៃការចូលរួមរបស់សហសេវិកក្នុងខេមប្រ៊ូវ គឺ៨៤% ដែលកើនឡើងចំនួន ៥% ធៀបនឹងឆ្នាំ២០២១ ដែលនេះបានបង្ហាញយ៉ាងច្បាស់ថា សហសេវិករបស់យើង មានការ ចូលរួម និងពេញចិត្តនឹងក្រុមហ៊ុន។

Vladimir អគ្គនាយកគ្រប់គ្រង ខេមប្រ៊ូវ មានប្រសាសន៍ថា៖ «លទ្ធផលដំបូង និងគួរឱ្យចាប់អារម្មណ៍បំផុតនោះគឺ ៩៦% នៃសហសេវិករបស់ ខេមប្រ៊ូវ បានចូលរួមស្ទង់មតិនេះ។ លទ្ធផលចូលរួមដ៏ខ្ពស់នេះបានបង្ហាញឲ្យឃើញថា សហសេវិករបស់យើងមានការប្តេជ្ញា ក្នុងការធ្វើឲ្យក្រុមហ៊ុនរបស់យើង ក្លាយជាទីកន្លែងការងារដែលមានភាពជោគជ័យ មានវិជ្ជាជីវៈ និងជាជម្រើសទីកន្លែងការងារដ៏មានភាពទាក់ទាញបំផុតមួយនៅកម្ពុជា។ នេះជាលទ្ធផលដ៏មានមោទកភាពមួយរបស់ពួកយើង»។

ទោះជាយ៉ាងណា យើងនៅមានចំណុចជាច្រើនទៀតដែលត្រូវរិះរកវិធីសាស្ត្រ ដើម្បីអភិវឌ្ឍ និងកែលម្អឲ្យកាន់តែប្រសើរបន្ថែមទៀត។ «គោលដៅរបស់យើង គឺកសាងក្រុមការងារឲ្យកាន់តែល្អប្រសើរ និងមានប្រសិទ្ធភាពការងារកាន់តែខ្ពស់ ព្រមទាំងមានបរិយាកាសការងារកាន់តែរីករាយ។ ការណ៍នេះ គណៈគ្រប់គ្រងក្រុមហ៊ុន នឹងធ្វើការជាមួយថ្នាក់ដឹកនាំ (ELT) ដើម្បីកំណត់ពីចំណុចអាទិភាព និងរៀបចំផែនការសកម្មភាព ដើម្បីអភិវឌ្ឍគោលដៅអាទិភាពដែលបានកំណត់ឲ្យកាន់តែប្រសើរ។

ពិពិធភាព សមធម៌ &បរិយាបន្ន (DE&I) គឺជាយុទ្ធសាស្ត្រអាជីវកម្មអាទិភាពមួយរបស់កាសស្បែរ ដែលនឹងជួយយើងឆ្ពោះទៅកាន់ការសម្រេចនូវមហិច្ឆតារបស់យើង ជួយជំរុញការអនុវត្តយុទ្ធសាស្ត្រអាជីវកម្ម ប្រតិបត្តិការអាជីវកម្ម ស្របតាមគោលបំណងរបស់យើង ដែលជាផ្នែកមួយនៃការរំពឹងរបស់អ្នកដឹកនាំកាសស្បែរ និងធានាថាអាជីវកម្មរបស់យើង ឆ្លុះបញ្ចាំងពីសហសេវិក អតិថិជនអ្នកប្រើប្រាស់ និងដៃគូអាជីវកម្មរបស់យើង។

លទ្ធផលនៃការស្ទង់មតិនេះ នឹងបង្កើតឲ្យមានការពិភាក្សាជារួម នៅក្នុងផ្នែកនីមួយៗទូទាំង ក្រុមហ៊ុន។ ហើយរាល់ចំណុចដែលបានពិភាក្សា នឹងត្រូវបង្កើតជាផែនការសកម្មភាព ជាក់លាក់ ដែលយើងនឹងយកមកអនុវត្ត ដើម្បីឆ្ពោះទៅកាន់វប្បធម៌ជោគជ័យរួមគ្នា។










# ការយកចិត្តទុកដាក់លើការផុសខាត់សមត្ថភាពជាប្រចាំ










គ្រឿងម៉ាស៊ីនដែលមានគុណភាពល្អ គឺត្រូវការការថែទាំ និងជួសជុលជាប់ជាប្រចាំ ដើម្បី បង្កើនអានុភាពខ្លាំង និងនៅតែស្ថិតនៅក្នុងលក្ខខណ្ឌប្រើប្រាស់កម្រិតខ្ពស់។ ទស្សនទានដូចគ្នានេះ ក៏ទំនងជាត្រូវបានអនុវត្ត សម្រាប់អ្នកដឹកនាំដែលមានទំនួលខុសត្រូវ និងដែលជាអ្នកកំណត់លទ្ធផលរំពឹងទុក និងធានានូវគុណភាពនៃលទ្ធផលដែលបានកំណត់នោះ។

នៅ ខេមប្រ៊ូវ យើងយកចិត្តទុកដាក់ និងផ្តល់តម្លៃខ្ពស់ចំពោះសមត្ថភាពអ្នកដឹកនាំរបស់យើង។ ខេមប្រ៊ូវ បានរៀបចំសិក្ខាសាលាស្តីពី ការរំពឹងទុកនៃភាពជាអ្នកដឹកនាំ នៅថ្ងៃទី១៤ ខែមិថុនា ដោយមានថ្នាក់ដឹកនាំពីផ្នែកខ្សែច្រវាក់ផ្គត់ផ្គង់ ១៤នាក់ចូលរួម។ សិក្ខាសាលានេះ សម្របសម្រួលដោយ Lisa Low នាយកគ្រប់គ្រងផ្នែកអភិវឌ្ឍសមត្ថភាពប្រចាំតំបន់អាស៊ី។

នៅក្នុងសិក្ខាសាលារយៈពេលមួយថ្ងៃនេះ អ្នកជំនាញរបស់យើង បានបំពាក់បំប៉ននូវ ចំណេះដឹងចាំបាច់ជាច្រើន ព្រមជាមួយនឹងវិធីសាស្ត្រសំខាន់នានា ដើម្បីធានាថាអ្នកដឹកនាំ ខេមប្រ៊ូវ យល់ដឹងច្បាស់អំពីថាតើអ្វីទៅ ដែលថ្នាក់ដឹកនាំកាសស្បែរ គ្រុប បានរំពឹងទុក ក៏ដូចជាដឹកនាំពួកគេ ទៅដល់ឱ្យកៀកបំផុតនឹងការរំពឹងទុកនោះ។

# ៥៣១ថ្ងៃ គ្មានគ្រោះថ្នាក់ដែលមិនបណ្តាលឱ្យបាត់បង់ពេលវេលាធ្វើការ

ZERO Accidents Culture

HEALTH & SAFETY

## 531 days

without LTA in Cambrew



នៅក្នុងចំណោមកំណត់ត្រាជោគជ័យជាច្រើន ដែល ខេមប្រ៊ូវ សម្រេចបានក្នុងពេលកន្លងមក យើងក៏សម្រេចបាននូវរយៈពេល ៥៣១ថ្ងៃ គ្មានគ្រោះថ្នាក់ដែលមិនបណ្តាលឱ្យបាត់បង់ពេលវេលាធ្វើការ (ZERO Lost-Time Accidents (LTA)) ដែរ គិតត្រឹមថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២៣។ នេះគឺជាសមិទ្ធផលដ៏គាប់ចិត្តមួយទៀតសម្រាប់យើង ដែលតែងតែប្តេជ្ញាចិត្ត និងប្រឹងប្រែងឥតឈប់ឈរ ក្នុងការបង្កើតបរិយាកាសដែលមានសុវត្ថិភាពនៅកន្លែងធ្វើការ។

គ្រោះថ្នាក់ដែលបណ្តាលឱ្យបាត់បង់ពេលវេលាធ្វើការ គឺជាគ្រោះថ្នាក់ដែលធ្វើឱ្យបុគ្គលិកមានរបួសក្នុងកម្រិតដែលត្រូវសម្រាកពីការងារ ឬធ្វើឱ្យប៉ះពាល់ផលិតភាពការងារ។ នៅក្នុងពិភពលោកដែលវិវត្តន៍យ៉ាងលឿននោះ គ្រប់វិនាទីសុទ្ធតែមានតម្លៃ។

ជាមួយនឹងជោគជ័យដ៏គួរឱ្យភ្ញាក់ផ្អើលនេះ អគ្គនាយកគ្រប់គ្រងខេមប្រ៊ូវ Vladimir បានថ្លែងអំណរគុណដល់សហសេវិកទាំងអស់។ លោកបានមានប្រសាសន៍ថា៖ «យើងមានសេចក្ដីសោមនស្សរីករាយជាខ្លាំង ក្នុងការអបអរនូវជោគជ័យ ៥៣១ថ្ងៃ ដែលគ្មានគ្រោះថ្នាក់ដែលមិនបណ្ដាលឱ្យបាត់បង់ពេលវេលាធ្វើការ។នេះសបញ្ជាក់ពីឆន្ទៈកិច្ចខិតខំប្រឹងប្រែងនិងការប្ដេជ្ញាយ៉ាងមោះមុតរបស់យើង ក្នុងការរួមគ្នាសម្រេចនូវមហិច្ឆតា «គ្មានវប្បធម៌គ្រោះថ្នាក់» ហើយយើងនៅតែបន្តរក្សអត្រាគ្មានគ្រោះថ្នាក់ដែលមិនបណ្ដាលឱ្យបាត់បង់ពេលវេលាធ្វើការសូន្យជារៀងរាល់ថ្ងៃ។

ទន្ទឹមនឹងនេះ Vladimir ក៏បានគូសបញ្ជាក់ពីសកម្មភាព នៅក្នុងរក្សាការអនុវត្តបទប្បញ្ញត្តិ ស្ដីពីសុខភាព និងសុវត្ថិភាព ក៏ដូចជាវិធាននានា ទាំងនៅក្នុង និងនៅក្រៅក្រុមហ៊ុន។ Vladimir បានបន្ថែមថា៖ «យើងមិនអាចធ្វើការងារដើម្បីថ្ងៃស្អែកកាន់តែប្រសើរនោះឡើយ ប្រសិនបើយើងព្រងើយកន្តើយ ចំពោះឥរិយាបថរបស់សហសេវិករបស់យើងនៅថ្ងៃនេះ»។

សូមយកចិត្តទុកដាក់ចំពោះសុខភាពរាងកាយ និងចិត្តរបស់យើង។ សុខភាពកាយចិត្តល្អជះឥទ្ធិពលល្អដល់សង្គមកាន់តែប្រសើរ។



# ខេមប្រ៊ូវ រក្សាបានប្រសិទ្ធភាពខ្ពស់នៃការគ្រប់គ្រងហានិភ័យ ក្នុងប្រតិបត្តិការរបស់ខ្លួន




ខេមប្រ៊ូវ តែងតែទុកសុខភាព ៥សុវត្ថិភាពរបស់បុគ្គលិក គឺជាអាទិភាពចម្បងនៅគ្រប់ កាលៈទេសៈ គ្រប់ទីកន្លែង ទាំងនៅខាងក្នុង ឬខាងក្រៅក្រុមហ៊ុន។

ខេមប្រ៊ូវ ទទួលបានពិន្ទុវាយតម្លៃខ្ពស់ អំពីការគ្រប់គ្រងហានិភ័យពី NSF International ចំនួន ៩៥ ពិន្ទុ ដែលពិន្ទុនេះស្ថិតក្នុងចំណាត់ថ្នាក់ល្អណាស់ និងបញ្ជាក់ថាយើងបានអនុវត្ត លក្ខខណ្ឌតម្រូវពេញលេញ ជាមួយគោលការណ៍តម្រូវពីគ្រុប។

ខេមប្រ៊ូវ មានឆន្ទៈអនុវត្តគ្រប់មធ្យោបាយ ដើម្បីធានាប្រសិទ្ធភាពនៃការគ្រប់គ្រងហានិភ័យ នៅក្នុងប្រតិបត្តិការអាជីវកម្មរបស់យើង និងបញ្ចៀសឱ្យបានការកើតមានឧប្បត្តិហេតុនានា ឬហានិភ័យធ្ងន់ធ្ងរ ដែលជះឥទ្ធិពលមិនល្អដល់មនុស្ស បរិស្ថាន សង្គម និងអាជីវកម្ម។ យើង គឺជាក្រុមហ៊ុនដែលមានទំនួលខុសត្រូវ មានការប្តេជ្ញាចិត្តខ្ពស់ និងបានប្រឹងប្រែង ឥតឈប់ឈរ ក្នុងការសម្រេចឱ្យបានគោលដៅចីរភាព «គ្រោះថ្នាក់សូន្យ» ត្រឹមឆ្នាំ២០៣០ ដែលជាមហិច្ឆតាមួយ ក្នុងចំណោមមហិច្ឆតាផ្សេងទៀត នៃគោលដៅចីរភាពថ្មី ស្តីពី បរិស្ថាន សង្គម និងអភិបាលកិច្ច រួមគ្នាឆ្ពោះទៅកាន់ហេរ្យូ និងលើសពីនេះ។

# យើងបន្តឈរលើភាពឥតខ្ចោះ និងសុវត្ថិភាព ដល់ទីបំផុត



គ្មានមួយថ្ងៃណាឡើយ ដែលនៅ ខេមប្រ៊ូវ មើលរំលងពីការអភិវឌ្ឍទៅរកឧត្តមភាពនោះ។ យើងមិនដែលរាថយចំពោះមហិច្ឆតារក្សាគុណភាពឥតខ្ចោះរបស់យើង ហើយព្រងើយកន្តើយជាមួយដៃគូប្រជែងនោះទេ។ យើងក៏មិនដែលលែងដៃអតិថិជនដ៏ស្មោះស្ម័គ្ររបស់យើង ដែលពួកគេតែងតែផ្តល់ទំនុកចិត្តលើផលិតផល និងក្រុមហ៊ុន របស់យើងនោះដែរ។ នេះគឺជាហេតុផលដែលជំរុញឱ្យអាជីវកម្មរបស់យើងនៅតែស្ថិតលើគន្លងដ៏ត្រឹមត្រូវ និងឆ្ពោះទៅរកការអភិវឌ្ឍឥតឈប់ឈរ។

ដើម្បីរក្សាបាននូវក្រមសីលធម៍ខ្ពស់ និងការជំរុញទឹកចិត្ត ខេមប្រ៊ូវ កាលពីថ្ងៃទី២៩ ខែមិថុនា បានរៀបចំទិវាសុវត្ថិភាពចំណីអាហារជាលើកដំបូង សម្រាប់សហសេវិក នៅអាហារដ្ឋានរោងចក្រស្រាបៀររបស់យើង នៅខេត្តព្រះសីហនុ។

គោលបំណងនៃការរៀបចំទិវានេះ គឺដើម្បីធ្វើឱ្យប្រាកដថា សហសេវិករបស់យើង ត្រូវបាន ផ្តល់ព័ត៌មានច្បាស់លាស់ អំពីវប្បធម៌សុវត្ថិភាពចំណីអាហារ បង្កើតផ្នត់គំនិតចូលរួមយកចិត្តទុកដាក់ក្នុងការលើកកម្ពស់សុវត្ថិភាពចំណីអាហារ។ អ្វីដែលកាន់តែសំខាន់ជាងនេះនោះ គឺសកម្មភាពនេះនឹងជួយជំរុញការបង្ការគ្រប់គ្រងហានិភ័យ និងអនុវត្តសុវត្ថិភាព ចំណីអាហារ តាំងពីការបន្សុទ្ធគ្រាប់ពូជ វត្ថុធាតុដើម ការផលិត រហូតដល់ផលិតផលរបស់យើង ត្រូវបានទទួលទាន។

យើងនៅតែរក្សាការបន្តស្វែងរកភាពល្អឥតខ្ចោះរបស់យើងដល់ទីបំផុត តាមរយៈការអនុវត្ត រឿងដែលត្រឹមត្រូវ ស្របតាមឆន្ទៈក្នុងការអភិវឌ្ឍកាន់តែប្រសើរសម្រាប់ថ្ងៃនេះ និងថ្ងៃស្អែករបស់យើង។

# អបអរកំណត់ត្រាថ្មី! ស្រាបៀរ អង្គរ អិចស្ត្រាស្តោត ទទួលបានពិន្ទុខ្ពស់លើភាពឈ្ងុយ និងរសជាតិ




សូមចូលរួមអបអរសាទរចំពោះកំណត់ត្រាថ្មី និងអស្ចារ្យមួយទៀត នៅក្នុងខ្សែច្រវាក់ផលិតកម្មនៃរោងចក្រស្រាបៀរ ខេត្តព្រះសីហនុរបស់យើង។

រោងចក្រស្រាបៀររបស់យើង ទទួលបានពិន្ទុខ្ពស់លើភាពឈ្ងុយនិងរសជាតិ ដល់ទៅ ៦.៤ សម្រាប់ស្រាបៀរ អង្គរ។ ដំណឹងដ៏រំភើបមួយទៀតនោះគឺ ស្រាបៀរ អង្គរ អិចស្ត្រាស្តោត ទទួលបានពិន្ទុដល់ទៅ ៦.៦ ឯណោះ។ ស្រាបៀរដែលទទួលបានពិន្ទុលើសពី ៦ គឺជាតួលេខខ្ពស់ជាទីគាប់ប្រសើរ និងជាលទ្ធផលបែតងដ៏អស្ចារ្យសម្រាប់យើង។ ការវាយតម្លៃប្រចាំខែនេះ ធ្វើឡើងដោយអ្នកត្រួតពិនិត្យលើភាពឈ្ងុយ និងរសជាតិស្រាបៀរប្រចាំតំបន់ ដែលមានមូលដ្ឋាននៅទីក្រុង Chongqing ប្រទេសចិន។

យើងសូមកោតសរសើរយ៉ាងខ្លាំងចំពោះកិច្ចខិតខំប្រឹងប្រែងយ៉ាងស្វាហាប់ និងមោះមុត របស់សហសេវិកនៅរោងចក្រស្រាបៀរ ខេត្តព្រះសីហនុ ក្នុងការសម្រិតសម្រាំងផលិត ស្រាបៀរដែលមានគុណភាពខ្ពស់ រសជាតិដ៏ល្អឥតខ្ចោះសម្រាប់អតិថិជនរបស់យើង។

CAMBREW LTD

Part of the Carlsberg Group

# អភិវឌ្ឍឲ្យកាន់តែប្រសើរ
# ទាំងថ្ងៃនេះនិងថ្ងៃស្អែក


No. 1881, Russian Boulevard, Phum Ta gnoun, Sangkat Kakab, Khan Posenchey, Phnom Penh, Kingdom of Cambodia

+855 (0) 16 880 695

info.kh@carlsberg.asia

Cambrew Ltd

Cambrewltd

Cambrew Ltd

Carlsberg Group
Carlsberg Cambodia